កំណាព្យ

បុប្ផាខ្មៅ

ជីវិតនិស្សិត

(សម្រង់អត្ថបទ)

បោះពុម្ពលើកទី១
ចំនួន ២.៥០០ក្បាល
ខែវិច្ឆិកា ១៩៧០

គយ សារុន

រក្សាសិទ្ធិ

ជំពាក់អ្នកអាន

នេះជាលើកដំបូង ដែលខ្ញុំផ្សាយអត្ថបទស្នាដៃ។

តាមពិត ខ្ញុំបានចាប់ផ្តើមរៀនសរសេរតាំងពីឆ្នាំ ១៩៥៨ គឺតាំងពីខ្ញុំនៅរៀនថ្នាក់ទី៤ នៃវិទ្យាល័យស៊ីសុវត្ថិ (បច្ចុប្បន្នវិទ្យាល័យភ្នំដូនពេញ) ។

ស្នាដៃកំណាព្យទី១របស់ខ្ញុំឈ្មោះ **ជីវិតនិស្សិត** ត្រូវបានជាប់លេខ៣ក្នុងការប្រឡងប្រជែងអក្សរសាស្ត្រឆ្នាំ ១៩៥៩ ខាងក្រសួងអប់រំជាតិ។ ខ្ញុំមិនបានបោះពុម្ពស្នាដៃនោះទេ ព្រោះយល់ថាគំនិតខ្ញុំនៅខ្ចីណាស់ ហើយខ្ញុំច្រើនសរសេរពីរឿងផ្ទាល់ខ្លួនផង។

ជោគជ័យដ៏តូចមួយនោះ គ្រាន់តែបានបណ្តុះចិត្តខ្ញុំឲ្យមានសេចក្តីសង្ឃឹមក្នុងការសរសេរប៉ុណ្ណោះ។ ខ្ញុំបានចិញ្ចឹមចិត្តនោះជានិច្ច រហូតមកដល់ឆ្នាំ១៩៦៥ ទើបខ្ញុំចង់សាកល្បងសរសេរម្តងទៀត។

កំណាព្យឈ្មោះបុប្ផាខ្មៅ ក៏កើតមានរូបរាងឡើង ហើយបានជាប់លេខ២ ក្នុងការប្រឡងអក្សរសាស្ត្រឆ្នាំ ១៩៦៧ ។ ប៉ុន្តែទោះបីជាឱ្យជាប់ដូច្នេះហើយក៏ដោយ មេប្រយោគកែវិញ្ញាសារបស់ខ្ញុំ មានលោកឈឹម ស៊ុម ,

ឈូក ម៉ៅ ជាដើមដែលខ្ញុំបានទៅជួបក៏បានសម្តែងនូវការ បារម្ភខ្លះដែរ។

ខ្ញុំត្រូវគិតច្រើនក្នុងរឿងនេះ...

ហើយក៏សម្រេចចិត្តមិនផ្សាយស្នាដៃនេះមួយ ទៀត, គ្រាន់តែបានបង្ហាញមិត្តភក្តិជិតដិតដែលចង់ឃើញ ប៉ុណ្ណោះ។

ឥឡូវនេះ ដោយសេរីភាពក្នុងការសរសេរក៏មាន ហើយ ឯមិត្តភក្តិក៏ចេះតែសួររក ខ្ញុំយល់ថាមិនគួរទុកចោល ស្នាដៃនេះតទៅទៀតទេ។ ម្យ៉ាងទៀត ខ្ញុំយល់ថា ការដែល ក្រសួងអប់រំជាតិក្តី សមាគមអ្នកនិពន្ធខ្មែរក្តី ខំរៀបចំការ ប្រឡងប្រជែងអក្សរសាស្ត្រ និងការដែលលោកអ្នកសប្បុរស ខំផ្តល់អំណោយដល់ជ័យលាភី មិនមែនគ្រាន់តែចង់លើក ទឹកចិត្តអ្នកសរសេរប៉ុណ្ណោះទេ គឺច្បាស់ជាមានឧត្តមគតិខ្ពង់ ខ្ពស់ចង់ឱ្យអក្សរសាស្ត្រខ្មែរលូតលាស់ដើម្បីជាប្រយោជន៍ ទូទៅ។ បច្ចុប្បន្ននេះ ខ្ញុំយល់ថាជាឱកាសដែលខ្ញុំត្រូវបម្រើ ឧត្តមគតិនេះហើយ ទោះបីបានច្រើនក្តី តិចក្តី។

ជាមួយនឹងស្នាដៃទី២ ឈ្មោះបុប្ផាខ្មៅ នេះ ខ្ញុំសូម ជូនស្នាដៃទី១ឈ្មោះជីវិតនិស្សិតផងដែរ ប៉ុន្តែគ្រាន់តែធ្វើ

សម្រង់អត្ថបទខ្លះដែលខ្ញុំនៅស្រឡាញ់ហើយមិនចង់ឱ្យបាត់បង់។

X X X

ក្នុងការផ្តើមផ្សាយស្នាដៃជាដំបូងនេះ ខ្ញុំសូមផ្ញើជូនតាមរយៈសៀវភៅនេះ នូវអំណរគុណដ៏ស្មោះរបស់ខ្ញុំចំពោះ៖

-ក្រសួងអប់រំជាតិ ដែលបានបណ្តុះសេចក្តីសង្ឃឹមឱ្យខ្ញុំជាដំបូងក្នុងការសរសេរ;

-សមាគមអ្នកនិពន្ធខ្មែរដែលបានបម្រើវប្បធម៌អក្សរសាស្ត្រខ្មែរពិតៗ;

-លោកអ្នកសប្បុរសដែលបានធ្វើអំណោយដល់ជ័យលាភី ដើម្បីការលូតលាស់នៃអក្សរសាស្ត្រខ្មែរ;

-អ្នកសរសេរផ្សាយស្នាដៃមុនៗខ្ញុំទាំងអស់ ដែលស្នាដៃរបស់លោកបានជាពន្លឺដល់ខ្ញុំ;

-លោក ញូង សឿង, ប៉ាយ ប៊ុក, កេង វាន់សាក់ ដែលនាំឱ្យខ្ញុំស្រឡាញ់កំណាព្យ, ចេះកំណាព្យ, យល់កំណាព្យតាមរយៈទស្សនាវដ្តីមិត្តសាលាបាលី, កម្ពុជសុរិយា, សៀវភៅសកុន្តលា, ចិត្តក្រមុំ, គុកកាមកិលេស;

-លោក ឈឹម ស៊ីម, ឈូក ម៉ឹង ម៉ៅ, ហូ តុង ហូ ដែលបានពិនិត្យស្នាដៃខ្ញុំ, សរសើរខ្ញុំ, រិះគន់ខ្ញុំ និងឱយ យោបល់ល្អៗ ដល់ខ្ញុំក្នុងការសរសេរ។

X X X

ជាបញ្ចប់នេះ ខ្ញុំអរគុណបងប្អូន ឃុន ស្រ៊ុន ដែលបាន សរសើរស្នាដៃខ្ញុំ តាមសារពត៌មាន និងតាមសៀវភៅ តំហើញ លេខ២ លេខ៣ ហើយថែមទាំងយកចិត្តទុកដាក់ ជួយចាត់ចែងបោះពុម្ពសៀវភៅនេះទៀតផង។

គយ សារុន

១០-១១-៧០

ឈ្មោះអត្ថបទ

១-បុព្វបទ.....

២-ឱដើមអម្ពិលទឹក.....

៣-«បទុមសុរិយោ» ផ្សាយរូប.....

៤-ទំព័រសៀវភៅ, ទំព័រជីវិត.....

៥-សួនផ្កឹត.....

៦-សីលធម៌សុំញ៉ែម.....

៧-សុរិយោក្តៅខ្លាំង.....

៨-សំណើចចំអកនៃទឹកច្រាក់.....

៩-វិលវិញឬអូន.....

១០-ខ្ញុំតាមមិនទាន់.....

១១-អភ័ព្វកំលោះស្រុកស្រែ.....

១២-ប្រតិភូក្បត់ពូជ.....

១៣-ក្រឡាស់ចិត្តទេដឹង.....

១៤-ឲ្យខ្ញុំសប្បាយម្តេចកើត.....

១៥-នគរប្តើងប្លែក.....

១៦-វិបីក្រមអ៊ូ.....

១៧-តិចឬច្រើន.....

១៨-ព្រះសង្ឃនិមន្តបិណ្ឌបាត្រ.....

១៩-សម្រោកមួយភ្លែត.....

២០-រកសូប់គេថាចាញ់.....

២១-អាសូរដើមដូង.....

២២-ស្តាយដួងចន្ទ្រា.....

២៣-ជីវិតនិស្សិត.....

២៤-នឹកផ្ទះ.....

២៥-លាការសិក្សា.....

២៦-សម្រេចចិត្ត.....

បុព្វបទ

ប្រហែលជាខ្ញុំវង្វេងទេដឹង បានជាឃើញការស៊ីផឹកសប្បាយនៅតាមផ្ទះបារ ខ្ញុំចេះតែនឹកគិតទៅដល់ការស្រេកឃ្លានខ្លះខាតនៃអ្នកក្រខ្សត់, ឃើញយុវសិស្សសាលាខ្លះហ៊ឺហា ហក់លោតរាំវែក ខ្ញុំគិតទៅដល់យុវជនខ្លះទៀតដែលស្លៀកពាក់ខោអាវចាស់ៗ ជួនកាលមានប៉ះដោយកន្ទែង ខ្លះប្រដាប់ប្រដារៀនសូត្រ ខ្លះលុយបង់សាលាឬលះបង់ការសិក្សាតែម្តង, ឃើញផ្ទះថ្មធំៗ រថយន្តថ្លៃៗ ខ្ញុំនឹកឃើញទៅដល់ការខ្វល់ខ្វាយរបស់មនុស្សដើម្បីរកវត្ថុទាំងនោះ ដោយជួនកាលលែងទាំងគិតគូរដល់ការត្រូវ-ខុស, ល្អ-អាក្រក់ទៀតផង។

ខ្ញុំឃើញអ្វីៗទាំងនោះ ដូចដែលអ្នកនិពន្ធនៃ "វិមាននរក" ឃើញសម្លៀកបំពាក់ស្រីបារជាក្រដាសប្រាក់ ២០០, ៥០០ ហើយគឺប្រាក់នេះ ដែលអ្នកក្ររកស៊ីបែកញើស ហូរញើស ច្រើនថ្ងៃខែទំរាំនឹងឈោងចាប់បាន ចំណែកឯ អ្នកមាន ឬអ្នក "រកបានងាយ" គេបែរជាយកទៅពង្រាយចោលទៅវិញ។

តែប្រសិនបើខ្ញុំមិនវង្វេងទេនោះ នុ៎ះគឺមកតែពីខ្ញុំធ្លាប់រស់នៅក្នុងទឹក-ផុក នៃស្រុកស្រែ, ធ្លាប់ចិញ្ចឹមជីវិតដោយសារបាយបាត្រព្រះសង្ឃដើម្បីរៀនសូត្រ, ធ្លាប់ចាកចោលដើងម៉ាវិទ្យាល័យទាំងទឹកភ្នែក ហើយបើយ៉ាងតិចណាស់ ក៏ខ្ញុំមិនចង់ឃើញយុវជនដែលកើតក្នុងត្រកូលខ្សត់ជួបនឹងឧបសគ្គគ្រប់បែបគ្រប់យ៉ាង មិនអាចនឹងរៀនសូត្រកសាងអនាគតឲ្យសមតាមប្រាជ្ញាស្មារតីរបស់ខ្លួននោះឡើយ។

គ.ស.

ខ្ទឹមអម្ពិលទឹក

១- គេកាត់គេច្រឹបគេរក្សា
ស្ថិតស្ថាវកាយាឲ្យឥតហ្មង
ពីខាង ពីលើ ធ្វើរបង
អ្នកផងសរសើរអម្ពិលទឹក ។

២- ថាជារុក្ខជាតិមានវាសនា
គេរាប់ប្រើការបានសន្ធឹក
មានដើមមានមែកបន្ទាញឹក
សន្ធឹកក៏ស្រស់រស់យូរយារ ។

៣- តែស្រស់តែស្អាតតែត្រឹមត្រង់
រូបខ្ទង់នេះសម្រាប់នរណា ?
សម្រាប់អម្ពិលទឹករុក្ខា ?
ឬថាសម្រាប់មនុស្សវិញទេ ? ។

៤- ដើមណាដែលរស់តាមធម្មជាតិ
លូតលាស់តាមមាឌមែកទន់ទេរ
សារិកាច្រៀវច្រៃបំពេ
ផ្កាផ្ទៃរាំរេតាមសូរខ្យល់ ។

៥- ឯដើមឈរត្រៀបតម្រៀបជួរ
សមគួរល្អគន់ពន់ពេកសល់
តែកំរើកដៃកន្ត្រែដល់
បានផលដាច់កត្រដរវស់ ។
៦- រស់រាប់ខែឆ្នាំចាំជីវិត
ក្រិនក្រៀមក្រពឹតឥតកម្ពស់
យាមផ្ទះឲ្យគេទទេសោះ
មានឈ្មោះតែត្រង់គេថាល្អ ។
៧- លុះថ្ងៃដែលប្រាក់កាសគេដល់
គេកាប់គ្មានសល់ពូជទុកត
គេគាស់ទាំងឫសចាក់គ្រឹះឫ
គេសរសើរល្អរបងដៃក ។

ភ្នំពេញ ១៨ មេសា ១៩៦៥

«បទុមសុរិយា»ផ្សាយរូប

១-បទុមសុរិយា ផ្សែងរូបប្រាថ្នា
រើសរកស្វាមី បានព្រះជិនវង្ស
តាមរករូបស្រី ដល់ក្រុងអសុរី
រួមរស់ស្នេហា ។

២-ក្រមុំសម័យ រាងរៀវច្រៃ
បង្ហាញកត្តា ញញឹមប្រិមប្រិយ
លើក្របទស្សនា- វដ្តី កាលណា
ខ្ញុំលួចកើតទុក្ខ ។

៣-ខ្ញុំសែនស្នេហា ចង់ផ្សែងវាសនា
ឱ្យបានជួបមុខ ទាស់ពីគ្មានឫទ្ធិ
ឬគ្មានទ្រព្យសុក ក្រែងស្រីមិនសុខ
ចិត្តចង់ស្នងស្នេហ៍ ។

៤-ម្យ៉ាងទៀតរូបស្រី ផ្សាយពេញផែនដី
បុរីនៃខ្មែរ មិនតែរូបមួយ
ខ្ញុំព្រួយគ្មានល្អែ ក្រែងមានគេដែរ
ចងចិត្តប្រចណ្ឌ ។

៥-នាំកើតច្បាំងគ្នា ដូចជាក្រុងមារ
យក្សសាលីកណ្ហា អួតអាងពាល់ខ្លួន
គុំកួនដុកជាន់ ខ្ញុំមិនក្លួចកាន់
សូមដកខ្លួនជយ ។

ភ្នំពេញ ១៩ មេសា ៦៨

ចំព័រស្បៃទៅ

ចំព័រជីវត

១- ពេលដែលខ្ញុំបើកទស្សនា-
វដ្តី កាលណាខ្ញុំសប្បាយ
មើលរូបក្មេីតក្មេីនក្មេចឃ្នានបាយ
រីករាយស្រស់ស្រាយហក់តាមខ្យល់។

២- មើលទ្បានចេញថ្មីល្បីថាធេីត
ខ្លួនវែងរាងស្ងេីតទេីបមកដល់
បេីត្រូវឆ្នោតធំសមលែងខ្វល់
ទិញមួយហេីយសល់លុយដេីរលេង។

៣- មើលម៉ូដទំនេីបធ្វេីសក់ថ្មី
ទឹកមុខលោកស្រីស្រស់ថ្ងាឈ្វេង
ថតបែរមុខក្រោយថែមស្តាំឆ្វេង
ខ្ញុំមុខជាគេងស្រមៃហេីយ!។

៤- មើលតារាងឯកនៃភាពយន្ត
ល្អគួយល្អគន់ណាស់លោកអើយ
ចេះធ្វេីឫកពាចេះឆ្វងឆ្វេីយ
ឃេីញហេីយជាប់ចិត្តឥតចង់ឃ្នាត។

៥- មើលការប្រឡងភាពសង្ហា
សង្ហាអស្ចារ្យថែមទ្បានទៀត
ធ្វើឫកធ្វើរាងចែកជូនញាតិ
បំណាច់ខំធ្វៀតមកពីធ្លាយ ។

* * *

៦- ក្នុងរូបអ្វីៗសុទ្ធតែល្អ
ក្តីផ្តៀងខ្មៅអាចសទៅវិញបាន
ខ្ញុំចង់មើលរូបទាំងប៉ុន្មាន
កំសាន្តសប្បាយធ្លាយជីវិត ។

ក្រុងតាកែវ ២១ សីហា ៦៥

សួនចិត្ត

១- រង់ៗមនុស្សជុំជិត
ជីវិតភ្លើតភ្លើនភ្ញេចក្នុងបារ
បទភ្លេងល្វេងល្វើយដាស់កាមា
សួនច្បារផ្ការីកពេលរាត្រី ។

២- ផ្ការីកស្ងួងៗក្នុងភ្លឺងពណ៌
អប្សរវេរាំតាមតន្ត្រី
ចម្រៀងល្ហែមល្ហែមផ្អែមសម្ដី
ស្រស់ស្រីនាងជាទេពកញ្ញា ។

៣- កំសាន្តក្នុងសួនទិព្វវិមាន
ចិត្តគ្មានកង្វល់ដល់ទុក្ខា
រសាត់បាត់ហើយរឿងខ្វោចផ្សា
ចិន្តាចាំចងតែថ្ងៃមថ្ងៃ ។

៤- ភ្ញេចភ្លាំងអស់ហើយការសិក្សា
ភ្ញេចហើយគ្រួសារជាប់ជើងដៃ
ភ្ញេចហើយទុក្ខសោកអ្នកដទៃ
គិតលៃម្ដេចបានប្រាក់រាំបារ ។

៥- អ្នកណាងាប់រស់អ្វីក៏ដោយ
គិតឲ្យតែអញបានហ៊ឺហា
ផឹកស៊ី ស៊ីផឹកដឹកសង្ហា
កំសាន្តសួនច្បារផ្កាឯងឆឹត ។

ភ្នំពេញ ២៤ មិថុនា ៦៥

សីលធម៌សុំញ៉ែម

១- ផ្ទះឬល្អហួសពីការស្មាន
ក្បែរផ្ទះមានឡានចតសេសសល់
ម្ចាស់ផ្ទះឈរសែ្មតមើលមកថ្នល់
ចុះផលបុណ្យអ្វីរបស់គេ ! ។

២- ឡានតូចថ្មីចែសបើកដំបូល
ចេញចូលលួនលេងគ្មានទំនេរ
ថ្ងៃល្ងាចលោកប្រុស-ស្រីទាំងទ្វេ
សង្ហាម៉្លេះទេគេធ្វើអ្វី ? ។

៣- ទំនិញទំនើបពីបរទេស
សុទ្ធល្អវិសេសផុតដែនដី
គេតែងនិយមទាំងប្រុសស្រី
ធ្វើអ្វីបានប្រាក់ទិញដូចចិត្ត ?

៤- ភាពយន្តទំនើបបង្ហាញច្បាស់
ឃើញណាស់តែអ្វីដែលប្រណីត
ខ្លួនក្រចិត្តលួតហួសកំហិត
តើគិតម្តេចផ្តាប់ស្តប់តណ្ហា ?

៥- បារមានហូរហែរពេញទីក្រុង
រាំឱបចិត្តស្ទុងក្នុងកាមា
គិតម្តេចឲ្យតែបានស្រីស្រា
នរណារស់ស្លាប់កុំខ្ចីខ្ញុល់ !

៦- រដូវមួយណាក៏ផ្កាស្រស់
ផ្ការីកទាំងអស់ឥតសេសសល់
ឲ្យតែផ្គាប់ចិត្តផ្កាដិតដល់
ខ្លះលុយកុំធ្ងល់ចៀសឲ្យឆ្ងាយ ! ។

៧- ផ្ទះឋ្ន, ឡាន, កុន, បារ, ស្រស់ស្រី
ហានសួគ៌លោកិយសែនសប្បាយ
សង្ឃឹមប្រាក់ខែម្តេចគ្រប់ចាយ
ត្រូវតែខ្ចល់ខ្ចាយខំ «រកស៊ី» ! ។

៨- ឱសីលធម៌អើយ! អ្នកកុំច្បាំង
តតាំងម្តេចឈ្នះធោមនារី
អញ្ជើញដកខ្លួនចូលគម្ពីរ
ទុកទីជូនទៅទ័ពតណ្ហា ។

ភ្នំពេញ ២៤ មិថុនា ៦៥

សុរិយាក្តៅខ្លាំង

១-សុរិយាល្ងាចថ្ងៃ ទន្សោងគោព្រៃ
រកស៊ីជើងភ្នំ តូចស៊ីដោយតូច
ធំស៊ីដោយធំ រកស៊ីជើងភ្នំ
ល្បាស់ព្រេចខ្ចីៗ ។

២-សុរិយាល្ងាចថ្ងៃ យុវជនសម័យ
ចង់ធ្វើមន្ត្រី ព្រោះឃើញគេមុន
ប្រពន្ធពីរបី ផ្ទះឬទ្បានថ្មី
មិនបាច់ខិតខំ ។

៣-សុរិយាល្ងាចថ្ងៃ មនុស្សលោកសម័យ
យកលុយជាធំ លុយជាចៅហ្វាយ
ប្រសើរឧត្តម ដឹកក្បាលឱ្យខំ
និយមតែលុយ ។

ភ្នំពេញ ១៣ កក្កដា ៦៥

សំណើចចំអកនៃទឹកប្រាក់

១- សាមគ្គី, សុចរិត, យុត្តិធម៌
មនុស្សធម៌, សីលធម៌, «ធម៌» ច្រើនណាស់
សរសេរហូរហៀរលើក្រដាស
ស្តាប់ឮក្រៃក្រាស់ក្នុងសម្តី ។
២- «ធម៌»នេះចេញមុខអើតតាមទ្វារ
បង្ហាញឫកពាស្រស់ប្រិមប្រិយ
ភប់រក«មិត្តភាព»រក«មេត្រី»
សេពគប់«ប្រណី»គប់«ករុណា» ។
៣- ខាងក្នុង«ទឹកប្រាក់»វាសប្បាយ
លួចមើលភ្នាក់ភ្នាយចំអកថា
«អាប្រាក់!អញនេះហើយខ្លាំងក្លា
សោយរាជ្យចេស្តា លើក្បាលមនុស្ស» ។

ភ្នំពេញ ៤ កក្កដា ៦៥

«ខលទញ្ចឹងអូន?»

១. តូច-ធំ ធំ-តូច ស្ពឹក-រីកសាយ
ចង្អៀត-ទូលាយ រួចចង្អៀត
វែង-ខ្លី ខ្លី-វែង រួចខ្លីទៀត
រួចបង្ហាញងៀតឱ្យច្បាស់ការ ។

២. ពីដើមមនុស្សស្រាតរួចចេះប៉ឹង
រួចប្រឹងដេរស្បៀកបិទកាយា
ស្បៀកពាក់ជុំជិតរឹតអាត្មា
យល់ថាបែបហ្នឹងទើបហៅល្អ ។

៣. ឥឡូវយល់ថាវែងលែងសម
តាំងខំវៀលវេះបញ្ចេញក
បង្ខើចដល់ភ្លៅនៅបន្ត
ចំហាមែមទៀតជូនកំសាន្ត ។

៤. យូរទៅប្រហែលជាគេប៉ឹង
ឬស្រាតទេដឹង?មិនហ៊ានស្មាន!
យ៉ាងណាក៏ដោយឱ្យតែបាន
តាមដានសម័យថ្មីឱ្យទាន់ !

ភ្នំពេញ ១២ កក្កដា ៦៥

ខ្ញុំតាមមិនទាន់

១- កញ្ញាច! កញ្ញាច! ក្មេងសម័យ
កន្ត្រាក់សរសៃឲ្យរាំរែក
អន្ទងបេះដូងឲ្យយំយែក
ហាស្រែករកស្រីស្រៀវកាមា ។

២- គេឱប គេរឹត គេត្រកង
បែរមុខវិលខ្នងពត់កាយា
គេងើប គេមុជ ក្រោមហត្ថា
ហ្នឹងហើយសួគ៌នាលោកិយ ។

៣- កុំអួសដៃខ្ញុំធ្វើអ្វីមិត្ត
រាំចុះកុះគិតខ្ញុំធ្វើអ្វី!..
ខ្ញុំមិនចេះរាំក្បាច់ខ្មែរថ្មី
ព្រោះអីខ្ញុំដើរមិនទាន់គេ ។

៤- និស្ស័យនៃខ្ញុំអស់ផ្លូវកែ
ខ្ញុំកើតនៅស្រែឥតចេះទេ
ខ្ញុំរស់នៅវត្តស្នួតបំពេ
ហ៊ានរាំលោកជេររាយបែកខ្នង ។

៥- កំហុសយ៉ាងធំ! ខ្ញុំមិនកែ
ទើបងើបពីស្រែស្គាល់ក្រុងម្តង
ទើបចេញពីវត្តផុតរបង
ម្តេចឡើយប្រឡងរាំញ័រញាក់ ។
៦- កំហុសយ៉ាងធំ! ខ្ញុំមិនកែ
ខ្ញុំខ្មែរភ្លេចស្រែរាំកន្ត្រាក់
ខ្មាសម៉ែ-ឪ-មា-មីង-មិត្តភ័ក្តិ
ខ្មាសបាយបាត្រស្រាក់ខ្មាសខ្លួនឯង។

ភ្នំពេញ ១៨ មេសា ៦៥

អត្ថកំណែះស្រុកស្រែ

១- ពីដើមនៅស្រុកស្រែចម្ការ
ស្នេហាសុខដុមកិរម្យណាស់
ក្រមុំកំលោះស្មោះស្ម័គ្រច្បាស់
ទាំងចាស់ទុំក៏ព្រមល្មមចិត្ត ។

២- ស្រឡាញ់គ្នាពិតឥតបែកបែរ
ឥតប្រែប្រួងប្រាសផ្តាសចោលមិត្ត
គិតតែរកស៊ីសាងជីវិត
សុចរិតត្រឹមត្រង់សាងក្តីសុខ។

៣- ឥឡូវក្រមុំចម្ការស្រែ
ចិត្តប្រែចោលកំលោះក្នុងស្រុក
ខ្ជិលដាំដកស្ទូងចង់ស្រណុក
ចាក់ស្មុគរកស្ម័គ្រអ្នកប្រាក់ខែ។

៤- កំលោះស្រុកស្រែបែរអន់អៀន
គ្មានបុណ្យស័ក្តិធ្វាក់ភ្លូវស្រែ
ម្តេចឡើយគេនឹងមកស្និទ្ធស្នេហ៍
ម្ល៉ោះហើយត្រូវតែរស់ក្រៀមក្រំ។

ភ្នំពេញ ២៥ មិថុនា ៦៥

ប្រតកូក្បត់ពូជ

១- អ្នកក្រត្រដរឲ្យកូនរៀន
ខំប្រឹងស្ទើរលៀនភ្នែកគ្រប់គ្នា
លក់គោក្របីជ្រូកមាន់ទា
ដីស្រែចម្ការសឹងមិនសល់។

២- កូនខ្លះផ្តេសផ្តាសមិនខំរៀន
ថែមហ៊ានយកលុយម៉ែឪផ្តល់
ចាយវាយហ៊ឹកហ៊ាក់ហក់តាមខ្យល់
មិនមានគិតដល់ញើសឪម៉ែ។

៣- កូនខ្លះគ្រាន់បើខាងរៀនសូត្រ
ស្ទុះលូតរបូតផុតដីស្រែ
ធ្វើការរាជការបានប្រាក់ខែ
ប៉ុន្តែភ្លេចអស់រឿងក្រីក្រ។

៤- ភ្លេចពូជពណ៌ពង្សវង្សអធន
ដែលរងទុក្ខធ្ងន់មកច្រើនត
ត្រូវគេព្រួតគ្នាច្របាច់ក
ត្រដរកខ្យល់ចាំតែស្លាប់។

៥- អ្នកក្របញ្ជូនឱយមករៀន
ឲ្យមានតម្រិះចេះប្រញាប់
ភ្នែកភ្លឺឃើញច្បាស់ឲ្យដាស់ប្រាប់
ម្តេចឡើយក្រឡាប់ក្បត់ពូជឯង។
៦- បែរជាព្រួតដៃនឹងអ្នកខ្ពស់
ទ្រគោះប្រឆាំងច្បាំងកំហែង
ថាក្រព្រោះខ្ចិលមិនប្រឹងប្រែង
ថាកម្មតាក់តែងពីព្រេងនាយ។
៧- បើតែម្ដឹងៗអ្នកខ្សោយខ្សត់
ប្រាកដជាគ្មានផ្លូវដោះស្រាយ
គេក្បត់ខ្លួនអស់ព្រោះជិនណាយ
ព្រោះគេសប្បាយក្ងេចពូជពណ៌។

ភ្នំពេញ ២៤ កក្កដា ៦៥

ក្រឡាស់ចិត្តទេដឹង?

១- ខ្ញុំនក្រចិត្តខ្ញុំក៏អ្នកក្រ
ឃើញមិត្តពលករខ្ញុំអាណិត
ឃើញក្មេងស៊ីឈ្នួលខ្ញុំខ្វោចចិត្ត
តែងគិតឈឺឆ្អាលជួយឈឺចាប់ ។

២- សព្វថ្ងៃ ខ្ញុំខំសាងវាសនា
សង្ឃឹមថ្ងៃណាទោះយូរធាប់
ថាក្រគង់ផ្ទាស់ច្បាស់ក្រឡាប់
ប្រញាប់ព្រួយថ្ងៃនៅ«ក្មេង»ដែរ[1] ។

៣- ចង់គ្រាន់ តែខ្ញុំបារម្ភណាស់
ក្រែងចិត្តខ្ញុំផ្ទាស់ក្រឡាស់ប្រែ
ចូលដៃក្រុមនោះដូចគេដែរ
រួចបែរគ្រហឹមដាក់មិត្តចាស់ ។

៤- ប្រសិនគ្រប់គ្នាតែបែបហ្នឹង
រៀនសូត្រចេះដឹងចិត្តក្រឡាស់
មិនបើកភ្នែកគ្នាឲ្យឃើញច្បាស់
ស្រឡះតែម្តងអស់ផ្លូវហើយ !...

ភ្នំពេញ ២២ កក្កដា ៦៥

(១) ស្រីហិតោបទេសថា ៖ បើរកទ្រព្យ-រកវិជ្ជា ត្រូវគិតថាខ្ញុំនមិនចាស់ មិនស្លាប់, បើរកធម៌ត្រូវគិតថា ខ្ញុំនត្រូវម្រឹត្យក្របួចសក់ពោកសម្ងាប់ឥឡូវហើយ។

ឱ្យខ្ញុំសប្បាយដូចម្តេចកើត?

១- នៅក្រុងខ្ញុំឃើញគេសប្បាយ
សម្បូរណ៌ប្រាក់ចាយឫកហ៊ឺហា
ទ្បានប្ចឺផ្ទះឬល្អអស្ចារ្យ
កូនល្ងោនស្រីស្រោស្រើបច្រៀងរាំ ។

២- មកស្រែខ្ញុំឃើញអ្នកស្រុកក្រ
ខ្លះស្រូវអង្កត្រដរខំ
រកត្រីបន្ទៃជួញដូរផ្សំ
នឿយហត់ក្រៀមក្រំព្រោះអត់ឃ្លាន ។

៣- ធ្លាយណាស់! ធ្លាយដូចដីនិងមេឃ
ធ្លាយពេករវាងក្រនិងមាន
កាលណាទើបទេពតាប្រទាន
ឱ្យមនុស្សសុខសាន្តប្រហែលគ្នា ?

ក្រុងតាកែវ ២២ សីហា ៦៨

«នគរថ្មើងប្លែក

សប្បាយតែភ្លែក

ក្នុងចិត្តរឯកម្ន»

(ក្រមង៉ុយ)

១- នគរប្តើងថ្កានបានចម្រើន
ផ្ទះឬក៏ច្រើនលូតកប់មេឃ
រថយន្តតូចៗច្រើនជ្រុលពេក
មនុស្សដេក«ផ្សែងព្រេង»ក៏ច្រើនដែរ ។

២- អ្នកមាន មានស្តុកទ្រព្យក្រៃក្រាស់
អ្នកក្រ ក្រណាស់ខ្វះគ្មានល្ហែ
អ្នកមានទិញសាច់គោឲ្យឆ្កែ
អ្នកស្រែម្ហាស់គោស៊ីប្រហុក ។

៣- កូនលោកអ្នកមានរៀនសាលា
សប្បាយហ៊ីហារឹតរីកមុខ
កូនសិស្សក្រខ្សត់ខ្វះស៊ីបុក
កើតទុក្ខខ្វះលុយបង់សាលា ។

៤- អ្នកខ្យល់ត្រូវក្តោងប៉ោងហោប៉ៅ
ហិចហើរហក់ទៅផ្លូវបនបារ
អ្នកច្រាក់ខែ«ងាប់»គេរាប់ថា
ជាមនុស្សយ៉ាបធាខ្វះអង្គរ ។
៥- សប្បាយមែនហើយលោកអ្នកមាន !
អ្នកក្រវាល់លានតឹងណែនក
ខំស្វឹតរកខ្យល់ស្វឹងក្អែកស
ត្រដរស្រែកថា «សប្បាយណាស់ ! » ។

ភ្នំពេញ ២៤ កក្កដា ៦៥

ទថីក្រមរ្ងូ

១- ធម្មជាតិដែនដួងចិត្តកវី
សប្បាយនឹងដីវែងអន្លាយ
នឹងទឹករលកលោមសាយ
នឹងមេឃខ្ពស់ធ្លាយដូចធ្លាយស្នេហ៍ ...

២- តាង៉ុយកវីប្រជាជន
ចិត្តធ្ងន់លើរាស្ត្រចម្ការស្រែ
ស្រឡាញ់ពេញចិត្តតែជាតិខ្មែរ
ទូន្មានគ្មានល្អែឲ្យក្ងាក់ខ្លួន ។

៣- ឥឡូវលោកតាសម្រាកហើយ
ម្តេចឡើយសម្រាកក្បែរបិនយួន
ពោធ៍កុន ផ្សារដែក សម្រែកផ្ទួន
ជួបជួនសូរស័ព្ទអាប់ខ្ទៀវខ្ទា ។

៤- នេះឬរង្វាន់នៃកវី
មានប្រជាប្រិយពេញរដ្ឋា
រង្វាន់លាក់ខ្លួនពួនអាត្មា

នៅកណ្តាលផ្សារគ្មានគេស្គាល់ ។

ភ្នំពេញ ១២ កក្កដា ៦៥

កំណាត់ចំណាំ

ឈ្មោះផ្លូវតូចមួយសម្រាប់ក្រមង៉ុយ ឈ្មោះវិទ្យាល័យមួយ និងសាលាបឋមសិក្សាមួយសម្រាប់ម៉ូនិក ។

(កំណាត់សរសេរថ្ងៃ ១២-១១-៧០)

តចម្កុច្រើន ?

១- ចៅអើយ! រូបតាប្រាថ្នាតិច!
ទ្រព្យធនបេះបិចលះជាទាន
បរិច្ចាគអស់ហើយលែងចង់មាន
ដូរសួគ៌និព្វានឋានសុខា ។

២- តាអើយរូបចៅប្រាថ្នាច្រើន
ក្រវើនខ្ចីឃ្មាតសព្វកិច្ចការ
ចង់មានតែក្នុងលោកនេះណា
មិនមានប្រាថ្នាសួគ៌និព្វាន ។

ភ្នំពេញ ១៩ មេសា ៦៥

ព្រះសង្ឃនិមន្តបិណ្ឌបាត្រ

១- នៅតាមស្រុកស្រែស្រុកចម្ការ
លេចតាមរុក្ខាមើលឃើញច្បាស់
ពណ៌លឿងភ្លឺថ្លាល្អត្រចះ
ឃើញហើយចិត្តជ្រះថ្លាបំផុត ។

២- ព្រះសង្ឃនិមន្តបិណ្ឌបាត្រ
ឃើញសមស្អាងស្អាតបរិសុទ្ធ
គួរនឹកដល់អង្គព្រះសម្ពុទ្ធ
ជាមកុដកំពូលសីលធម៌ ។

៣- នៅតាមទីក្រុងមនុស្សរោរជន់
ព្រះសង្ឃនិមន្តត្រាច់គោចរ
បិណ្ឌបាត្រតាមផ្លូវដ៏អ៊ូអរ
ឃើញហាក់មិនល្អមិនសមសួន ។

៤- ព្រះសង្ឃនិមន្តផ្ទាល់លើដី
អស់លោកប្រុសស្រីខ្មែរចិនយួន
សុទ្ធយានជំនិះជិះរៀងខ្លួន
គាប់ជួនពេលខ្លះចង់ប៉ះផង ។

៥- ហ្នឹងហើយក្រុងធំមនុស្សប្លុំប្លើង
ខ្ពង់ខ្ពស់ខ្ញាំងឡើងជាចម្បង
នៅស្រែមនុស្សល្ងង់ទាបកន្ទង
តែសមគ្មានឆ្គងក្នុងឥរិយា ។

ក្រុងតាកែវ ២៥ សីហា ៦៥

សម្រាកមួយភ្លែត

១- ឈប់សិន! ឈប់សិន! វិទ្យាសាស្ត្រ
លឿនណាស់! លឿនណាស់! ចក្រអ្នកឯង
ខ្ញុំខំផាយតាមហត់ហួងហែង
សុំឈប់ប្រជែងផ្អាកចលនា ។

២- ខ្ញុំក្រាលស្មឹកឈើក្រោមម្លប់ស្វាយ
ដាក់កាយទម្រេតកើយក្រមា
ខ្យល់បក់ល្ហែកៗល្ហើយកាយា
ចិន្តាហោះហើរហិចទៅឆ្ងាយ... ។

៣- កាលដើមចង្វាក់នៃជីវិត
ហាក់ឥតរន្ធើនក្តៅក្រហាយ
រង្វើលៗលយអន្ទាយ
សប្បាយហូរហែតាមធម្មតា ។

៤- រទេះគោបរង៉ើតង៉ត
ត្រេតត្រយទ្រុយៗកាត់ព្រឹក្សា
សូរស័ព្ទសត្វយំឆ្ងែងឆ្ងើយគ្នា
កំព្រាដួងចិត្តដូចនេនទុំ ។

៥- ឯនាយដងទង់ចុងជហ្វា
ដំបូលវិហារកុដិមួយដុំ
លេចតាមចន្ទោះដើមឈើជុំ
មើលឃើញជ្រងំសមជ្រះថ្លា ។
៦- ឯនុំះដំណែលប្រាង្គប្រាសាទ
ស្អាងស្អាតសុទ្ធសឹងក្បាច់សិលា
មិនដឹងប៉ុន្មានតដូនតា
តម្បូវព្រឹក្សាដុះព័ទ្ធព័ន្ធ ...

ភ្នំពេញ ៣ កក្កដា ៦៥



៧- កាលគ្មានទឹកកកមនុស្សគិតថា
ធឹកទឹកស្រះថ្លាធ្លាញ់ណាស់ហើយ
កាលគ្មានឡានលឿនមនុស្សព្រងើយ
ដើរលេងរំហើយគ្មានប្រញាប់ ។
៨- ក្រុងរីកធំឡើងត្រូវទិញខ្យល់
ទិញសព្វគ្មានសល់គ្រប់ប្រដាប់
ទិញណាស់ខ្វះណាស់ខ្វល់ស្ទើរស្ងាប់
ស៊ីណាស់រឹតធាប់ឃ្លានមកវិញ ។



៩- ចម្រើនសម្រាប់តែចម្រើន
គិតទៅគ្មានកើនលើសជាថ្មី
ខំលូតនាំហត់អត់បានអ្វី
គួរតែលែងខ្ជិរត់តាមទៀត ។
ក្រុងតាកែវ ២២ សីហា ៦៥

រកស្រុកគេថាចាញ់

១- ខំរក រកណាស់ រឹតខ្វះណាស់
ខំរៀនដល់ចាស់នៅមិនចប់
បាននេះខ្វះនោះមិនចេះសព្វ
មិនស្កប់តណ្ហាមនុស្សសម័យ ។

២- ចង់ដកខ្លួនចេញរស់ដោយព្រៃ
ជីវភាពប្រពៃសប្បាយក្រៃ
រស់តាមធម្មជាតិរាល់ថ្ងៃ
ចិត្តលែងចង្រៃអន្ទះសា ។

៣- តែធ្វើដូច្នេះគេថាចាញ់
មិនខ្មេះរត់ខ្មាញ់ពួនអាត្មា
ថែមគេមើលងាយនិយាយថា:
វាអន់បានជានៅក្នុងព្រៃ ។

ភ្នំពេញ ២៣ កក្កដា ៦៥

អាសូរដើមដូច

១- យូរហើយដូចដុះក្នុងភូមិម្ត
ដើមជាងលូតល្អមានផ្ទៃផ្កា
ស្រាប់តែផ្តាច់ឫសផ្តាច់អាហារ
គេថាគាស់ដឹកយកទៅដាំ! ។

២- ល្ងាចនេះដូចដុះក្បែរសាលា
លោកអ្នករាជការខំថែទាំ
តុបតែងស្រោចទឹកយ៉ាងជោគជាំ
ថ្នាក់ថ្នមមុតមាំខ្លាចដូចដួល ។

៣- ព្រឹកឡើងបុណ្យសម្ពោធសាលា
មនុស្សមូលខ្វៀវខ្វាមីរខ្មាញ់ខ្ជួល
ញញឹមប្រិមប្រិយចាំទទួល
ស្រុះស្រួលចោមជុំសម្តេចឪ ។

៤- ដើមដូចជាច់ឫសសប្បាយដែរ
រេរាំហូរហែតាមក្បែរផ្លូវ
ញញឹមស្វាគមសម្តេចឪ
មើលអស់លោកត្រូវបានមេដៃ ។

៥- ព្រឹកដ៏រីករាយកន្ទួងទៅ
ដួងនៅម្នាក់ឯងកណ្តាលថ្ងៃ
សូរ្យសែងក្តៅដុតគ្មានសំចៃ
ដួងក្សយ័ចោលរូបកណ្តាលក្រុង ។

ភ្នំពេញ ១២ កក្កដា ៦៥

ស្គាយដួងចន្ទ្រា

១- ខ្ញុំស្រឡាញ់ដួងចន្ទ្រាពេញបូណ៌មី
រឿងរង្សីភ្លឺត្រចះច្បាស់មេឃា
ស្អាតបរិសុទ្ធមូលក្រឡង់ក្នុងនភា
ខ្ញុំនិន្ទ្រាមិនលក់ឡើយពេលរាត្រី ។

២- ខ្ញុំស្រឡាញ់ដួងចន្ទ្រាភ្លឺត្រជាក់
ពន្ធឺប្រាក់ស្រោបដួងចិត្តជនប្រុសស្រី
ឲ្យសប្បាយភ្លើតភ្លើនចិត្តឥតខ្វល់អ្វី
ភ្លេចក្រក្រីក្តីសោកសៅក្នុងជីវិត ។

៣- ខ្ញុំស្រឡាញ់ដួងចន្ទ្រាមូលក្រឡង់
ហាក់ដូចវង់កក្រែកល្បាណគូស្នេហ៍ស្និទ្ធ
នាងញញឹម ខ្ញុំសង្ឃឹម សប្បាយចិត្ត
ហាក់បានជិត រឹតរួមរក្ស ស្ម័គ្រគនិដ្ឋា ។

៤- ខ្ញុំស្រឡាញ់ដួងចន្ទ្រាជាសាក្សី
នៃសេចក្តីស្មោះស្ម័គ្រចិត្តស្និទ្ធស្នេហា
នៃក្រមុំនិងកំលោះគូសង្សារ
ដែលប្រាថ្នាបានជាគូរួបរួមកាយ ។

៥- ខ្ញុំស្រឡាញ់ដួងចន្ទ្រាជាល្បែងក្មេង
ម្តាយពោលលេងឲ្យកូនតូចពនសុំបាយ
សុំសម្ល, ទឹកបំពង់, ចេក, ដូង, ស្វាយ
កូនសប្បាយញ៉ាំចិបៗសើចក្អឺកៗ ។
៦- ខ្ញុំស្រឡាញ់ដួងចន្ទ្រាមានពោធិធំ
ជីដូនខ្ញុំប្រាប់ដូច្នេះមកជាញឹក
មើលទៅឃើញមានឫសគល់ដើមមែកស្វឹក
ក្រោមពោធិព្រឹក្សដូនចាស់រវៃអំបោះ ។
៧- ខ្ញុំស្រឡាញ់ដួងចន្ទ្រាហៅសសាង្គ
ព្រះឥន្ទ្រស្អាងរូបទន្សាយទុកនៅនោះ
រំឭកកាលពោធិសត្វគិតសង្រ្គោះ
ព្រាហ្មណ៍ដោយស្ទុះលោតចូលភ្លើងជាអាហារ ។
៨- ខ្ញុំស្រឡាញ់ដួងចន្ទ្រាហៅលោកខែ
នៅស្រុកខ្មែរពិធីដ៏ថ្លៃថ្លា
អកអំបុកដើយមើលចំដួងចន្ទ្រា
បន់ទេវតាសូមខេមរាបានភ្លើងភ្លាន ។
៩- ខ្ញុំស្រឡាញ់ដួងចន្ទ្រានៃកវី(១)
ក្នុងរាត្រីនាំអារម្មណ៍ឲ្យក្សេមក្សាន្ត

ខ្ញុំនរំភើបហាក់អណ្តែតទៅឆ្ងាយបាន
ក្ងេចខ្ញុំនប្រាណសប្បាយតាមកាំរស្មី ។
១០- ខ្ញុំតូចចិត្តនឹងពួកអ្នកវិទ្យាសាស្ត្រ
ម្តេចក៏ផ្តាសធ្វើកាំជ្រួចបាញ់ពីដី
ចង់ទៅយកដួងព្រះចន្ទ ពិភពថ្មី
ហេតុចង់ល្បីខ្លាយកេរ្តិ៍ឈ្មោះបោះនាមា។
១១- ខ្ញុំមិនចង់ឲ្យមនុស្សលោកសុទ្ធហ្មងសៅ
ដូចធ្យូងខ្មៅទៅប្រឡាក់ដួងចន្ទ្រា
ដែលបរិសុទ្ធផុតមន្ទិលផងនានា
គួរបូជាស្រឡាញ់ស្មោះពីហឫទ័យ ។
១២- ឱ!សែនស្តាយដួងចន្ទ្រាជាសកល
ដែលតែងផ្តល់គ្រប់បំណងដោយប្រពៃ
ម្តេចឡើយអ្នកវិទ្យាសាស្ត្រគិតបំភ្លៃ
យកចន្ទ្រថ្ងៃជាកម្មសិទ្ធិឲ្យសៅហ្មង ។

---

(១) អត្ថបទតទៅនេះរហូតចប់ត្រូវបានសូត្រក្នុង
ពិធីចែករង្វាន់នៅវិមានរដ្ឋាភិបាល ។
ភ្នំពេញ ២៦ មិថុនា ៦៥

ជីវតនិស្សិត

ទំព័រខាងក្រោយតទៅនេះ ជាអត្ថបទកំណាព្យ ដែលខ្ញុំស្រង់ពីស្នាដៃទី១របស់ខ្ញុំឈ្មោះ «ជីវិតនិស្សិត»។ ដូចខ្ញុំបានជំរាបអ្នកអានហើយថា ដោយស្នាដៃនេះខ្ចីពេក ខ្ញុំមិនបោះពុម្ពទេ ប៉ុន្តែខ្ញុំស្គាយអត្ថបទខ្លះដែលខ្ញុំស្រឡាញ់ ដូច្នេះបានជាខ្ញុំស្រង់អត្ថបទខ្លះនោះមកបញ្ចូលក្នុងសៀវភៅនេះផង។

បើអត្ថបទទាំងនោះមិនមានប្រយោជន៍ចំពោះអ្នកអានទេ ខ្ញុំសុំគ្រាន់តែទុកវាសម្រាប់រំឭកអនុស្សាវរីយ៍មួយទៅចុះ។

គ.ស.

ឆឹកឆ្នះ (១)

១- នៅសល់បីថ្ងៃ តែយូរពេកក្រៃ
បីថ្ងៃកើតទុក្ខ ជិតវ៉ាកង់ហើយ
ម្តេចឡើយ«ជាប់គុក» គួរបានរីកមុខ
បានទៅកំសាន្ត ។

២- កំសាន្តសប្បាយ ជួបមិត្តទាំងឡាយ
ដែលយើងធ្លាប់បាន រស់ជាមួយគ្នា
នោះវិញមិនខាន ហៅសែនសុខសាន្ត
សម្រានចិន្តា ។

៣- យើងកូនអ្នកស្រែ សប្បាយណាស់ដែរ
ប្រញាប់ម្ដីម្នា វិលទៅស្រុកវិញ
ជួបមិត្តមីងមា ម៉ែឪយាយតា
គ្រួសាររីករាយ ។

៤- នឹងជួបមាន់ទា ជួបគោឆ្កែឆ្មា
ដែលនៅឯនាយ ដែលធ្លាប់ស្រឡាញ់
ធ្លាប់ខឹងជេរវាយ នឹងឃើញទ្រង់ទ្រាយ
ដីស្រែឡើងវិញ ។

៥- តាអើយ! រូបចៅ តាំងពីបែកទៅ
នៅឯភ្នំពេញ តែងនឹកមកតា
ឯទីនេះវិញ ទទូចទន្ទេញ
ចង់តែមកជួប ។
៦- យាយអើយ! រូបចៅ តាំងពីបែកទៅ
អស់យូរខែខួប តែងនឹកមកយាយ
ចង់តែមកជួប ព្រោះខានបានរួប
រួមសំដីយូរ ។
៧- ឪអើយ! កូននឹក ទាំងល្ងាចទាំងព្រឹក
បន់ឲ្យតែគ្រួ ឱយឈប់កាលណា
នឹងបានគិតគូរ មកផ្ទះឲ្យយូរ
ជួបជុំគ្រួសារ ។
៨- ម៉ែ! ម៉ែ! ម៉ែ! ម៉ែ! កូននឹកគ្មានល្អៀ
បែកម៉ែថ្ងៃណា កូនស្រក់ទឹកភ្នែក
នឹកម៉ែអស្ចារ្យ ម៉ែធ្លាប់រក្សា
ថ្នាក់ថ្នមរូបកូន ។
៩- ឯណាបួនខ្ញុំ បួនតូចបួនធំ
បាត់ទៅណាសូន្យ អូ! នោះមកហើយ

មក! មក! អាអូន បងនឹកមកប្អូន
ឯងរាល់គ្នាណាស់ ។
១០- គោយើងនៅទេ? ទាំងកូនទាំងមេ
មេក្មេងមេចាស់ ចុះអាពពាល
តើវានឹកម្ចាស់ ដើមនៃវាខ្លះ
ដែរឬគ្មានទេ ។
១១- ឆ្កែបងអាលួ ខានឃើញវាយូរ
ព្រោះគ្មានទំនេរ ខាននាំវាចេញ
ដេញសត្វដូចគេ ម្ល៉េះវាលួចដេរ
បងខ្លះទេដឹង ។
១២- ឯណាវរទេះ ដែលបងធ្លាប់ជិះ
មានចងកណ្តឹង វរទេះគោលឿន
បរបត់ក្បែរស្នឹង រួចទៅក្បែរបឹង
ទៅមើលស្រូវស្រែ ។
១៣- ម៉ែចទៅឆ្នាំនេះ បានផលគ្រាន់បេះ
ច្រូតកាត់ខ្លះដែរ ឬមួយស្កកអស់
ពាសពេញទាំងស្រែ ដោយពីរបីខែ
គ្មានឃើញក្ងៀងសោះ ។

១៤- ទាំងក្រុមគ្រួសារ ទាំងញាតិកា
ឆ្កែឆ្មាទាំងអស់ ទាំងជ្រូកមាន់ទា
ខ្ញុំស្រឡាញ់ស្មោះ ចំពោះឥតខ្ចោះ
ជាងអ្វីនានា ។
១៥- ព្រោះអ្នកទាំងនេះ ដែលបានចេះរិះ
ទាំងអស់គ្រប់គ្រា ស្រឡាញ់ខ្ញុំពិត
ឲ្យមកសិក្សា ចំណេះវិជ្ជា
ជារស្មីប្រាណ ។
១៦- វិជ្ជាជាទ្រព្យ យ៉ាងប្រសើរគាប់
គួរឲកឱ្យបាន ត្រូវខំរៀនសូត្រ
ឲ្យចេះចំណាន ថ្ងៃក្រោយទៅបាន
ក្សេមក្សាន្តជីវិត ។

វត្តកែវព្រះភ្នែង មេសា ៥៨

(១) កំណាព្យនេះកាលសរសេរខ្ញុំដាក់ឈ្មោះថា «គិតទុកបីថ្ងៃមុន» តទ្បាវខ្ញុំសុំកែឈ្មោះថា «នឹកផ្ទះ» វិញ។ កំណាព្យនេះត្រូវបានសូត្រក្នុងពិធីចែករង្វាន់នៅក្នុងវាំង។

លាការសិក្សា

១- សព្វថ្ងៃខ្ញុំក្មេី អារម្មណ៍ខ្ញុំហើរ
ហោះហិចទៅឆ្ងាយ គ្មានទីកំណត់
កត់យកសប្បាយ ព្រួយចិត្តព្រួយកាយ
សំណាងមិនល្អ ។

២- ខ្ញុំនឹកសង្វេគ តែងព្រួយចិត្តពេក
ព្រួយព្រោះខ្វះខ្លួនក្រ រៀនបានតិចតួច
ខំទាំងត្រដរ ឥឡូវនេះក៏
ត្រូវតែឈប់រៀន ។

៣- ចេញពីសាលា ចោលការសិក្សា
ចោលអស់របៀន លាអស់ពួកមិត្ត
លាគ្រូបង្រៀន លាទាំងគ្រឹះស្ថាន
ដែលធ្លាប់សិក្សា ។

៤- លាហើយណាមិត្ត ខ្ញុំលាអ្នកពិត
ចេញពីសាលា លាទាំងអាល័យ
ឥតបីនឹងថា ខ្ញុំត្រូវចាប់ការ
បិញ្ចឹមជីវិត ។

៥- ព្រោះខ្ញុំនេះក្រ គ្មានលុយបន្ត
ការសិក្សាពិត ត្រូវតែចាប់ការ
ចិញ្ចឹមជីវិត លាហើយណាមិត្ត
អ្នកនៅរៀនចុះ ។
៦- ខំទៅសម្ងាញ់ រៀនយកឈ្នះចាញ់
ខំទាំងស្រីប្រុស ខំរៀនដើម្បី
ល្បាញល្បីកេរ្តិ៍ឈ្មោះ ត្រូវមិត្តខំលុះ
ទម្លុះអវិជ្ជា ។
៧- អវិជ្ជាគ្មានជោគ គឺជាមេរោគ
ចង្រៃមហិមា តែងសុីខួរក្បាល
មនុស្សគ្រប់គ្នា លុះតែស្ទុះស្ងា
រៀនទើបចៀសបាន ។
៨- វិជ្ជាជាថ្មាំ មិត្តអើយចូរចាំ
ខំរកឱ្យបាន ចៀសភាពល្ងិតល្ងង់
ដែលនាំថោកប្រាណ ទើបយើងនឹងបាន
ជាពលរដ្ឋល្អ ។
៩- ខ្ញុំដឹងខ្លួនដែរ ខ្ញុំខំគ្មានល្អែ
តែដោយខ្លួនក្រ រុលទៅមិនរួច

ព្រោះក្រវឹកក្រ បានជាខ្ញុំចរ
ចាកការសិក្សា ។
១០- ខ្ញុំលាមិត្តទៅ ចិត្តខ្ញុំចាំនៅ
នឹងមិត្តគ្រប់គ្នា សង្ឃឹមជានិច្ច
ថាមិត្តមិនរា បំពេញវិជ្ជា
ទុកសម្រាប់ខ្លួន ។
១១- ឯរូបខ្ញុំវិញ ខ្ញុំពេញទោម្នេញ
ដោយនឹកស្តាយខ្លួន រៀនមិនបានច្រើន
គ្មានចេះមាំមួន មិនបានសមសួន
ចំនួនចំណាត់ ។
១២- តែទោះយ៉ាងណា ត្រង់ការសិក្សា
ខ្ញុំមិនលះបង់ ខ្ញុំខំរៀនទៀត
លុះត្រាអស់ចង់ សូមឱ្យមិត្តស-
ង្ឃឹមជឿខ្ញុំចុះ ។

ភ្នំពេញ មេសា ៥៨

សម្រេចចិត្ត

១- គិតទៅគេងទៅនៅតែព្រួយ
ជីវិតខ្ញុំមួយគ្មានវាសនា
ជីវិតខ្ញុំមួយតើយ៉ាងណា
គ្មានបានសិក្សាច្រើនជ្រៅជ្រះ ។

២- គិតផងគេងផងគងថ្ងាសគិត
ផ្ទះនៅមិនជិតរឹតឃើញផ្ទះ
ច្បាស់ណាស់ជីវភាពឃើញជាក់ច្បាស់
ក្រីក្រកម្មក្រាស់ពេញក្រក្រី ។

៣- ចិត្តអាណិតគ្រួសារខ្វោចចិត្ត
ស្តីទៅព្រួយចិត្តមិនចេញស្តី
ខ្វីអស់គំនិតនាំគិតខ្វី
ទ្រាំមិនគិតអ្វីស៊ូតែទ្រាំ ។

៤- រៀនពីរបីឆ្នាំពេលមករៀន
ក្រំក្រៀមឥតមានស្រោកក្រៀមក្រំ
ខំណាស់ខាងរៀនស្គាល់ពីខំ
រៀនដោយសន្សំខំប្រឹងរៀន ។

៥- គ្រួសារក្រណាស់ក្រមួយគ្រួ
គ្មានទ្រព្យល្អគួរសមរកគ្មាន
មានតែស្រែវស្រែទ្រព្យដែលមាន
បានជាទ្រាំរៀនទៅមិនបាន ។

៦- ចំណេះតិចតួចស្ហួចចំណេះ
ក្បាន្តបានដែរអេះ សុខក្បែមក្បាន្ត
សាន្តសុខជីវិតឥតសុខសាន្ត
ធ្វើអ្វីទៅបានការអ្វីធ្វើ ។

,,,,,

១០- មានតែផ្ទះមួយផ្ទះមានមួយ
រង់ចាំជំហានកុំរេរង់
ខ្ទង់ក៏មិនមែន មិនមែនខ្ទង់
ធ្វើគ្រូខ្ចីចង់ត្រូវតែធ្វើ ។

,,,,,

១៧- មិត្តអើយមើលទៀននៅផ្ទះមិត្ត
ធាប់ឆេះមិត្តអុជទៀនឆេះធាប់
ស្រាប់វិនាសរូបមិត្តឃើញស្រាប់
ភង់រូបទៀនស្ងាប់បាត់រូបភង់ ។

១៨- ទៀនវិនាសពិតប៉ុន្តែទៀន
វាងវៃមែនមានគិតវៃវាង
ទៀងជាក់បំភ្លឺគេជាក់ទៀង
ភ្លឺគេបំព្រាងឱ្យគេភ្លឺ ។
១៩- ការធ្វើគ្រូគេគឺជាការ
ឮហើយគេថាយើងធ្លាប់ឮ
ឈឺចាប់មានរោគជួនកាលឈឺ
ឱ្យតែសិស្សភ្លឺដោយគ្រូឱ្យ ។
២០- ទៀនដូចជាគ្រូគ្រូដូចជាទៀន
ខ្សោយរូបសុខភាពតែងអន់ខ្សោយ
ក្រោយទៅរីងខ្ជិនជាខាងក្រោយ
ភ្លឺបុះខ្ញុំឱ្យសិស្សបានភ្លឺ ។